# អង្គការក្រៅរដ្ឋាភិបាលផ្តោតការចាប់អារម្មណ៍ បន្តអំពីដំណើរការចុះឈ្មោះអ្នកបោះឆ្នោត



លោក អ៊ឹម សួស្តី



លោក ខេព នីថា




សន្និសីទកាសែតរបស់សង្គមស៊ីវិលស្តីពីដំណើរការសំអាតបញ្ជីអ្នកបោះឆ្នោត

ដោយយោងទៅតាម សវនកម្មដែលគួរឱ្យជឿទុកចិត្តលើបញ្ជីឈ្មោះអ្នកបោះឆ្នោត នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញថា ៨៨.៨% នៃអ្នកមានសិទ្ធិបោះឆ្នោត ទាំងអស់បានចុះឈ្មោះ។ ប៉ុន្តែ១១.២% នៅមិនទាន់បានចុះឈ្មោះ បោះឆ្នោតនៅឡើយទេ ដែលតួលេខនេះបានបញ្ជាក់ នូវការប៉ាន់ប្រមាណដោយផ្ទាល់របស់គ.ជ.ប ពីអ្នកមានសិទ្ធិបោះឆ្នោតចំនួន ៦៨២០០០

តទៅទំព័រទី ២គ

តមកពីទំព័រ ១៨

ដែលចាំបាច់ ត្រូវចុះឈ្មោះនោះពិតជាត្រឹមត្រូវ ។ គ.ជ.ប. មានបំណងសម្អាត និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលចាប់ផ្ដើមពីថ្ងៃទី១៥ ខែកញ្ញា រហូតដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៧ ។

លោក *ហង្ស ពុទ្ធា* នាយកប្រតិបត្តិនៃអង្គការនិកហ្វិច (NICFEC) បានផ្ដល់ជាអនុសាសន៍ថា " *យោងទៅតាមលទ្ធផល នៃការស្រាវជ្រាវរបស់ពួកយើង បានឱ្យដឹងថា ការចុះឈ្មោះ អ្នកមានសិទ្ធិបោះឆ្នោត វាមានសារៈសំខាន់ខ្លាំងជាងការសម្អាតបញ្ជីឈ្មោះ អ្នកបោះឆ្នោត នៅថ្ងៃទី១៥ ខែកញ្ញារហូតដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៧ ។ វាគឺជាអទិភាពចាំបាច់បំផុត របស់ គ.ជ.ប. សម្រាប់ខែក្រោយ ។បើសិនជា គ.ជ.ប. លុបឈ្មោះអ្នកបោះឆ្នោត ចេញពីបញ្ជីសម្រាប់ដំណើរការចុះឈ្មោះបោះឆ្នោត វាចាំបាច់ទាមទារឱ្យមានការផ្ដល់នូវភស្តុតាងច្បាស់លាស់ថា ទិន្នន័យលើបញ្ជីឈ្មោះនោះវាមិនត្រឹមត្រូវ* " ។

សវនកម្មបញ្ជីឈ្មោះ អ្នកបោះឆ្នោត (VRA) ឬការត្រួតពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត គឺជាការវាយតម្លៃមួយ ដែលមានគុណភាពជាលក្ខណៈប្រព័ន្ធ និងវិទ្យាសាស្ត្រនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ហើយបានរៀបចំឡើង កាលពីថ្ងៃទី១០-១៤ ខែសីហា ឆ្នាំ២០០៧ ដោយអង្គការនិកហ្វិច (NICFEC) និងខុមហ្វ្រែល (COMFREL) ដែលជាអង្គការ សង្កេតការណ៍បោះឆ្នោតក្រោមជំនួយបច្ចេកទេសពីមជ្ឈមណ្ឌល សម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ (CAS) និងវិទ្យាស្ថានជាតិ ប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) ដែលមានទីស្នាក់ការ នៅសហរដ្ឋអាមេរិក ។ អ្នកស្ម័គ្រសង្កេតការណ៍របស់អង្គការទាំងពីរ ត្រូវបានគេរៀបចំឱ្យបំពេញការងារ នៅតាមឃុំចំនួន៣៨០ ទូទាំងប្រទេសកម្ពុជា ដើម្បីសម្ភាសន៍អ្នកមានសិទ្ធិបោះឆ្នោតចំនួន៣៧៩៦នាក់ ។ ទាំងឃុំ និងអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងនេះ ត្រូវបានគេជ្រើសរើសតាមបែបវិធីសាស្ត្រស្ថិតិ ។ ទិន្នន័យគ្រោងសម្រាប់កំហុស ដែលអាចកើតចំនួន ៣.៥% ជាមួយនឹងកម្រិត ដែលអាចជឿទុកចិត្តបានចំនួន ៩៥% ។

សវនកម្ម បញ្ជីឈ្មោះអ្នកបោះឆ្នោត (VRA) ឬការត្រួតពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត គឺជាការធ្វើតេស តាមវិធីពីរបែប ។ " *តេសពីបញ្ជីទៅមនុស្ស* " ("List-to-People Test") ធ្វើឡើងដោយអ្នកសង្កេតការណ៍ ធ្វើការជ្រើសរើសយកឈ្មោះ ពីបញ្ជីចុះឈ្មោះអ្នកបោះឆ្នោត តាមបែបស្ថិតិ ហើយបន្ទាប់មកធ្វើការទំនាក់ទំនងទៅកាន់អ្នកបោះឆ្នោតនោះ ដើម្បីសាកសួរពីពត៌មានដែលត្រឹមត្រូវរបស់គាត់ ។ ចំណែកឯ " *តេសពីមនុស្សទៅបញ្ជី* " ("People-to-List Test") គេជ្រើសរើសអ្នកដែលមានសិទ្ធិបោះឆ្នោត នៅកន្លែងផ្សេងៗគ្នា (តាមវិធីសាស្ត្រចាប់លេខរៀង) ពីសហគមន៍ ហើយពត៌មានទាក់ទង នឹងការចុះឈ្មោះបោះឆ្នោត នឹងត្រូវធ្វើការត្រួតពិនិត្យធៀបនឹងបញ្ជីឈ្មោះ អ្នកបោះឆ្នោត ។

ផ្ដើមចេញពីការធ្វើតេស ពីបញ្ជីទៅមនុស្ស ("List-to-People Test") ជាង ៣/៤ នៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលស្មើនឹង៧៧.៣% គឺមានលក្ខណៈត្រឹមត្រូវ ។ ចំនួនដល់ទៅ១០.៥% ជាចំនួននៃអ្នកបោះឆ្នោត ដែលអាចនឹងផ្លាស់ទីលំនៅជាអចិន្ត្រៃយ៍ ឬជាបណ្ដោះអាសន្ន ។ ប៉ុន្តែបើតាមការរួមបញ្ចូលទាំងពីរតេស យើងឃើញថា បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលមានឈ្មោះអ្នកបោះឆ្នោត ត្រឹមត្រូវមានចំនួន ៨៦.២% ហើយ ៨៨.១% សម្រាប់អាសយដ្ឋានដែលត្រឹមត្រូវ ។ លោក *ជេរ៉ូម ជឿង* (Jerome Cheung) នាយកប្រចាំប្រទេសនៃអង្គការ អ៊ិន ឌី អាយ (NDI) បានមានប្រសាសន៍ថា " *ខ្ញុំជម្រុញឱ្យ មានការប្រុងប្រយ័ត្នក្នុងការសម្អាតបញ្ជីឈ្មោះ បោះឆ្នោត នៃបញ្ជីដែលមានលក្ខណៈត្រឹមត្រូវ ។ ម្យ៉ាងទៀត វាហាក់បីដូចជាបង្ហាញពីសមាមាត្រមួយសំខាន់ ចំពោះអ្នកបោះឆ្នោតដែលស្នាក់នៅក្រៅឃុំ-សង្កាត់ របស់ពួកគាត់ជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ ហើយអ្នកទាំងនោះអាច ឬក៏មិនអាចនឹងត្រូវត្រឡប់មកបោះឆ្នោត នៅក្នុងឃុំ-សង្កាត់របស់គាត់វិញ ។ ប្រសិនបើជាអ្នកបោះឆ្នោតទាំងនេះ បានចុះឈ្មោះបោះឆ្នោតលើសពីម្ដង មានន័យថា វាកាន់តែធ្វើឱ្យយើងកាន់តែយកចិត្តទុកដាក់ ទៅលើការត្រួត*